1

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**តុលាការកំពូល**

សំណុំរឿងរដ្ឋប្បវេណី

លេខ: ១៨០

ចុះថ្ងៃទី១៧ ខែមិថុនា ឆ្នាំ២០០២

៣៣៣*៤៤

**នាមនាមប្រជារាស្ត្រខ្មែរ**

**តុលាការកំពូល**

<u>សាលដីកា</u>

លេខ: ១៧៩

ចុះថ្ងៃទី១៦ ខែសីហា ឆ្នាំ២០០៤

បានបើកសវនាការជំនុំជំរះជាសាធារណ: នៅថ្ងៃទី១៦ ខែសីហា ឆ្នាំ២០០៤ ដោយមានសមាសភាពដូចតទៅ :

| | | | |
|---|---|---|---|
| ១-ឯកឧត្តម | **ឃឹម ប៉ុណ្ណ** | | ជាប្រធានក្រុមប្រឹក្សាជំនុំជំរះ |
| ២-លោក | ស៊ិន | ឌឹម | ជាចៅក្រម |
| ៣-លោក | ប្រាក់ | គឹមសាន | ជាចៅក្រមរបាយការណ៍ |
| ៤-លោក | ជីវ | កេង | ជាចៅក្រម |
| ៥-លោក | ម៉ុង | មុន្នីចរិយា | ជាចៅក្រម |
| លោក | **សុខ** | **ម៉ៅ** | ក្រឡាបញ្ជី |

តំណាងមហាអយ្យការ

| | | | |
|---|---|---|---|
| លោក | **ឃួន** | **ចាន់ថា** | ជាព្រះរាជអាជ្ញា |

ដើម្បីជំនុំជំរះលើបណ្តឹងសាទុក្ខពីសាលដីការដ្ឋប្បវេណីលេខ៧៧"ខ"ចុះថ្ងៃទី២៧ ខែសីហា ឆ្នាំ២០០១ នៃសំណុំរឿងរដ្ឋប្បវេណីលេខ ៧២៥ ចុះថ្ងៃទី២៧ ខែវិច្ឆិកា ឆ្នាំ២០០០ របស់សាលាឧទ្ធរណ៍រវាង :

ដើមចោទឈ្មោះ**យិន សុខន** (ជាចុងបណ្តឹងសាទុក្ខ) ភេទស្រី អាយុ៤៥ឆ្នាំ ជាតិខ្មែរ មុខរបរធ្វើស្រែ ទីលំនៅភូមិស្រែសៀម ឃុំជីរោទី២ ស្រុកត្បូងឃ្មុំ ខេត្តកំពង់ចាម ។ ឪពុកឈ្មោះយិន សុគន្ធ "រ" ម្តាយឈ្មោះឌី កាន "រ" ។

ចុងចម្លើយឈ្មោះ **ទុយ ទេន** (ជាម្ចាស់បណ្តឹងសាទុក្ខ)ភេទប្រុស អាយុ៤១ឆ្នាំ ជាតិខ្មែរ មុខរបរធ្វើស្រែ មានទីលំនៅបច្ចុប្បន្នភូមិស្រែសៀម ឃុំជីរោទី២ ស្រុកត្បូងឃ្មុំ ខេត្តកំពង់ចាម ។ ឪពុកឈ្មោះពុធ ទុយ "ស" ម្តាយឈ្មោះសុខ សៅ "រ" ប្រពន្ធឈ្មោះសាយ អឿន "រ" ។

ចុងចម្លើយឈ្មោះ **ទុយ ទុំ** (ជាម្ចាស់បណ្តឹងសាទុក្ខ)ភេទប្រុស អាយុ៤៨ឆ្នាំ ជាតិខ្មែរ មានទីលំនៅបច្ចុប្បន្ន ភូមិស្រែសៀម ឃុំជីរោទី២ ស្រុកត្បូងឃ្មុំ ខេត្តកំពង់ចាម ។ ឪពុកឈ្មោះពុធ ទុយ "ស" ម្តាយឈ្មោះសុខ សៅ "រ" ប្រពន្ធឈ្មោះពៅ ហេង ។

**កម្មវត្ថុចណ្តឹង** : ប្តឹងសុំបើកផ្លូវរទេះទំហំ ៤ម គុណ ៥០ម ។

បានឃើញបណ្តឹងសាទុក្ខលេខ ២៩៤ ចុះថ្ងៃទី២៧ ខែសីហា ឆ្នាំ២០០១ របស់ឈ្មោះទុយ ថេត និងទុយ ថុន ប្តឹងមិនសុខចិត្តនឹងសាលដីការដ្ឋប្បវេណីលេខ៧៧"ខ" ចុះថ្ងៃទី២៧ ខែសីហា ឆ្នាំ២០០១ របស់សាលាឧទ្ធរណ៍ ត្រង់ចំណុចនៃសេចក្តីសំរេចទាំងមូល ។

បានឃើញសំណុំរឿងរដ្ឋប្បវេណីលេខ ១៨០ ចុះថ្ងៃទី១៧ ខែមិថុនា ឆ្នាំ២០០២ របស់តុលាការកំពូល ។

តាមពាក្យបណ្តឹងចុះថ្ងៃទី៣១-០១-២០០០ របស់ដើមចោទឈ្មោះឃិន សុខន ថា ផ្លូវរទេះគោ ដែលស្ថិតនៅជាប់របងផ្ទះឈ្មោះទុយ ថេត គឺជាផ្លូវសាធារណៈដែលប្រជាជន និង នាងខ្ញុំដើរចេញចូលតាំងពីឆ្នាំ១៩៧៩ មកដល់សព្វថ្ងៃនេះ ។ តែឥឡូវឈ្មោះទុយ ថេត ,ទុយ ថុន បានបិទផ្លូវរទេះនេះមិនឱ្យនាងខ្ញុំ និងប្រជាជនដើរចេញចូល ហើយយកដីផ្លូវធ្វើជាកម្មសិទ្ធិរបស់ខ្លួនវិញ ហេតុនេះហើយ ទើបនាងខ្ញុំប្តឹងសុំឱ្យបើកផ្លូវរទេះនេះវិញ ព្រោះជាផ្លូវសាធារណៈ ។

បានឃើញសាលក្រមរដ្ឋប្បវេណីលេខ ១៣៤"ក"ចុះថ្ងៃទី១៥ ខែមិថុនា ឆ្នាំ២០០០ របស់តុលាការខេត្តកំពង់ចាម ដែលមានខ្លឹមសារនៃសេចក្តីសំរេចដូចតទៅ :

១-ទទួលពាក្យបណ្តឹងរបស់ដើមចោទឈ្មោះឃិន សុខន ចុះថ្ងៃទី៣១ ខែមេសា ឆ្នាំ២០០០ ទុកជាត្រឹមត្រូវតាមទំរង់ច្បាប់ និង គតិច្បាប់ ។

២-បង្គាប់ឱ្យឈ្មោះទុយ ថេត +ទុយ ថុន បើកផ្លូវនៅខាងក្រោយផ្ទះរបស់ខ្លួនពីជើង ទៅត្បូង ។ ផ្លូវនេះមានទទឹង ៣ម និងបង្គាប់ឱ្យឈ្មោះទុយ ថេត បើកផ្លូវខាងជើងដីរបស់ខ្លួនចេញទៅផ្លូវលំ ផ្លូវនេះមានទទឹង ៤ម បណ្តោយ ៣៧ម ។ ឯឈ្មោះឃិន សុខន ក៏ត្រូវរក្សាផ្លូវខាងត្បូងផ្ទះឈ្មោះទុយ ថុន ចេញទៅផ្លូវលំតាមលំនាំដែលមានស្រាប់ ។ ហាមដាច់ខាតមិនឱ្យភាគីណាយកផ្លូវនេះជាផ្លូវឯកជន ហើយត្រូវរក្សាផ្លូវនេះជាផ្លូវសាធារណៈសំរាប់ប្រជាជនប្រើទូទៅ។ លំនាំផ្លូវមានក្នុងគំនូសបង្ហាញទីតាំងស្រាប់ ។

៣-រឹបអូសប្រាក់ប្រដាប់ក្តី គឺពន្ធចុះបញ្ជីក្តី ពន្ធហ្វីងចំនួន ១៨០០៛ រង្វាន់ក្រឡាបញ្ជីកាន់ហិបប្រាក់ ២០០៛ ប្រាក់អង្កេតស៊ើបសួរ ៥.០០០៛ សរុប ៧.០០០៛ ប្រាក់នេះកាត់យកពីប្រាក់ដែលដើមចោទបានបង់ទុករួចហើយ នៅពេលដែលសាលក្រមនេះចូលជាស្ថាពរ ទើបបង្គាប់ឱ្យចុងចម្លើយបង់សងមកដើមចោទវិញ ពន្ធសមាមាត្រគ្មាន ។

៤-សាលក្រមនេះ ជំនុំជំរះ និងប្រកាសចំពោះមុខដើមចោទ និងចុងចម្លើយ ។ បើកសិទ្ធិឱ្យគូភាគីប្តឹងឧទ្ធរណ៍ក្នុងកំណត់ច្បាប់ ។

បានឃើញបណ្តឹងឧទ្ធរណ៍លេខ ៤៩ ចុះថ្ងៃទី១៤ ខែកក្កដា ឆ្នាំ២០០០ របស់ឈ្មោះទុយ ថេត និង ទុយ ថុន ប្តឹងមិនសុខចិត្តនឹងសាលក្រមរដ្ឋប្បវេណីលេខ ១៣៤ "ក" ចុះថ្ងៃទី១៥ ខែ

មិថុនា ឆ្នាំ២០០០ របស់តុលាការខេត្តកំពង់ចាម ត្រង់ចំណុចសាលក្រមទាំងមូល ។

បានឃើញសាលដីការដ្ឋប្បវេណីលេខ ៧៧"ខ" ចុះថ្ងៃទី២៧ ខែសីហា ឆ្នាំ២០០១ របស់សាលាឧទ្ធរណ៍ ដែលមានខ្លឹមសារនៃសេចក្ដីសំរេចដូចតទៅ :

១-ទទួលបណ្ដឹងឧទ្ធរណ៍ចុះថ្ងៃទី១៤-៧-២០០០ របស់ឈ្មោះទុយ ចេត,ទុយចុន ទុកជាត្រឹមត្រូវតាមទម្រង់ច្បាប់ តែបដិសេធចោលដោយខាសនឹងគតិច្បាប់ ។

២-តំកល់សាលក្រមរដ្ឋប្បវេណីលេខ ១៣៤"ក" ចុះថ្ងៃទី១៥ ខែមិថុនា ឆ្នាំ ២០០០ របស់តុលាការខេត្តកំពង់ចាម ទុកជាបានការពេញទាំងមូល ។

៣-រឹបអូសយកប្រាក់ប្រដាប់ក្ដីជាន់សាលាឧទ្ធរណ៍ចំនួន ១៣.០០០៛ ដែលដើមបណ្ដឹងឧទ្ធរណ៍ បានបង់រួច គឺពន្ធចុះបញ្ជីក្ដី និងពន្ធហ្លឹង ២៥៥០៛ រង្វាន់ក្រឡាបញ្ជីកាន់ហិបប្រាក់ ៤៥០៛ ចំណាយក្នុងកិច្ចប្រគល់ដីកាកោះ ៥.០០០៛ ចំណាយលើអាជ្ញាធរតុលាការ ៥.០០០៛ សរុប ១៣.០០០៛ ។

សាលដីកានេះ ជំនុំជំរះ និងប្រកាសជាសាធារណៈចំពោះមុខគូក្ដី បើកផ្លូវប្ដឹងសាទុក្ខក្នុងកំណត់ច្បាប់ ។

បានឃើញបណ្ដឹងសាទុក្ខលេខ ២៩៤ ចុះថ្ងៃទី២៧ ខែសីហា ឆ្នាំ២០០១ របស់ឈ្មោះទុយ ចេត និងទុយ ចុន ប្ដឹងមិនសុខចិត្តនឹងសាលដីការដ្ឋប្បវេណីលេខ៧៧"ខ" ចុះថ្ងៃទី២៧ ខែសីហា ឆ្នាំ២០០១ របស់សាលាឧទ្ធរណ៍ ត្រង់ចំណុចនៃសេចក្ដីសំរេចទាំងមូល ។

បានស្ដាប់របាយការណ៍របស់ចៅក្រមរបាយការណ៍

បានស្ដាប់តំណាងមហាអយ្យការបានធ្វើសេចក្ដីសន្និដ្ឋានថា : សាលាឧទ្ធរណ៍បានសំរេចត្រឹមត្រូវតាមគតិច្បាប់ហើយ សូមក្រុមប្រឹក្សាជំនុំជំរះសំរេចតាមច្បាប់ ។

បានស្ដាប់ចម្លើយរបស់ឈ្មោះទុយចុន នាពេលសវនាការថា : ផ្លូវនេះមិនមែនសាធារណៈទេ ប្រជាជនក៏មិនដែលដើរតាមផ្លូវនេះដែរ ខាងត្បូងមានផ្លូវ ខាងជើងមានផ្លូវ ខាងលិចជាដីយិន សុខន ខាងត្បូងជាដី យិន សុខន ខាងជើងក៏ដីយិន សុខន ដែរ តើហេតុអ្វីបានជាយិន សុខន មកសុំបើកផ្លូវខាងក្រោយជាប់ដីខ្លួនទៀត បើបើកផ្លូវគឺពិតជាចូលដីខ្លួនមិនខាន . ផ្លូវខាងក្រោយនេះគេបិទយូរមកហើយ បិទត៦គ្នា សព្វថ្ងៃគ្មាននរណាដើរទេ ចំពោះផ្លូវខាងជើងផ្ទះខ្ញុំបើកយូរហើយ ។ សូមជួយរកយុត្តិធម៌ខ្ញុំផង ។

បានស្ដាប់ចម្លើយរបស់ឈ្មោះ ទុយ ចេត នាពេលសវនាការថា : ខ្លួនមិនបានបិទផ្លូវទេ ផ្លូវខាងក្រោយផ្ទះបិទយូរហើយ បិទទាំងអស់គ្នា ហេតុអ្វី យិន សុខន មកបើកវិញ បើខាងក្រោយ ខាងត្បូង ខាងជើងដីខ្លួន គឺសុទ្ធតែជាដីយិន សុខន ទាំងអស់ហើយ ។ សូមរកយុត្តិធម៌ផង ។

បានស្ដាប់ចម្លើយរបស់ឈ្មោះយិន សុខន នាពេលសវនាការថា : ដីខាងត្បូង, ខាងលិច,

ខាងជើង ដីលំនៅដ្ឋានចុងចម្លើយ ជាដីរបស់ខ្លួនទាំងអស់ ក្រោយមកចុងចម្លើយបានបិទផ្លូវខាងក្រោយផ្ទះ ឯអ្នកភូមិផ្សេងៗទៀតមិនតវ៉ាទេ ហើយបិទតៗគ្នា ឈប់ប្រើរហូតសព្វថ្ងៃ គ្មាននរណាដើរទេ ។

- ក្រោយពីបានស្តាប់របាយការណ៍របស់ចៅក្រមរបាយការណ៍
- ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់តំណាងមហាអយ្យការ
- ក្រោយពីបានស្តាប់ចម្លើយគូភាគី
- ក្រោយពីបានពិភាក្សាត្រឹមត្រូវតាមច្បាប់ហើយ

## តុលាការកំពូល

- យល់ឃើញថា បណ្តឹងសាទុក្ខលេខ ២៩៤ ចុះថ្ងៃទី២៧ ខែសីហា ឆ្នាំ២០០១ របស់លោកទុយ ថេត និងទុយ ថុន ធ្វើឡើងក្នុងកំណត់ច្បាប់ តុលាការកំពូលអាចលើករឿងនេះ មកជំនុំជំរះបានតាមមាត្រា១៤ នៃច្បាប់ស្តីពីការចាត់តាំង និងសកម្មភាពរបស់សាលាជំរះក្តី ។

- យល់ឃើញថា តុលាការកំពូលបានចេញលិខិតបង្គាប់ឱ្យចុងចម្លើយ ធ្វើសារណាការពារផលប្រយោជន៍របស់ខ្លួនរួចហើយ ។ តាមចំណារចុះថ្ងៃទី០៩-០១-២០០៣ របស់ជំទប់លេខ៣ ឃុំជីរោ៣ ថាបានប្រគល់លិខិតឱ្យដំណឹងដល់សាម៉ីខ្លួនឈ្មោះទុយ ថុន និងទុយ ថេត រួចហើយ ។ ប៉ុន្តែសាម៉ីខ្លួនទាំង២នាក់ ពុំព្រមផ្តិតមេដៃទេ ។ ឯភាគីដើមចោទបានធ្វើសារណាដាក់ជូនតុលាការកំពូល រួចហើយ ។

- យល់ឃើញថា ការដែលចុងចម្លើយឈ្មោះទុយ ថេត បានលើកឡើងនាពេលសវនាការនៅតុលាការថ្នាក់ក្រោមថា ខ្លួនពុំព្រមឱ្យបើកផ្លូវរទេះទំហំ៤ម x ៥០ម នៅចំហៀងផ្ទះខ្លួនដោយហេតុថា ផ្លូវនេះមិនមែនផ្លូវរទេះសាធារណៈ នោះជាការពុំត្រឹមត្រូវទេ ពីព្រោះថា :

ចុងចម្លើយខ្លួនឯងបានទទួលស្គាល់ថា ផ្លូវទំនាស់មានតាំងពីសង្គមចាស់មកម្ល៉េះ ហើយផ្លូវនេះ ខ្លួនទើបតែបិទនៅឆ្នាំ២០០០ ដោយយកបង្គោលដើមត្នោត ៣-៤ ដើមទៅបិទ ។ ម្យ៉ាងទាំងសាក្សីដើមចោទ ទាំងសាក្សីចុងចម្លើយសុទ្ធតែបានទទួលស្គាល់ថា ផ្លូវចំហៀងផ្ទះចុងចម្លើយមានតាំងពីសង្គមចាស់មកម្ល៉េះ ។

- យល់ឃើញថា ការដែលសាលាឧទ្ធរណ៍ និង តុលាការខេត្តកំពង់ចាមសំរេចអោយចុងចម្លើយបើកផ្លូវខាងក្រោយផ្ទះខ្លួននោះ ជាការពុំត្រឹមត្រូវទេ ពីព្រោះផ្លូវនេះលែងទៅជាតម្រូវការសេវាភាពរួម ឬតម្រូវការសាធារណៈទៀតហើយ ពីព្រោះដីខាងក្រោយផ្ទះ ខាងជើងផ្ទះ និងខាងត្បូងផ្ទះ ក្លាយទៅជាដីរបស់ដើមចោទតែម្នាក់ឯងហើយពុំមានជនណាផ្សេងប្រើប្រាស់ផ្លូវនេះឡើយ ។

-យល់ឃើញថា សាលដីការដ្ឋប្បវេណីលេខ ៧៧"ខ" ចុះថ្ងៃទី ២៧-០៨-២០០១ របស់សាលាឧទ្ធរណ៍ដែលបានសំរេចសេចក្តីមកនេះ មានលក្ខណៈត្រឹមត្រូវតាមទំរង់ និងគតិច្បាប់ហើយ

លើកលែងការឱ្យបើកផ្លូវខាងក្រោយផ្ទះចុងចម្លើយដែលត្រូវទុកជាមោឃៈ ។

**ហេតុដូច្នេះ**

**វិនិច្ឆ័យសេចក្តីទំនោះចុងក្រោយ**

១-ទទួលបណ្តឹងសាទុក្ខលេខ២៨៤ ចុះថ្ងៃទី២៧ ខែសីហា ឆ្នាំ២០០១ របស់លោក ទុយចេតនិងទុយថុន ទុកជាត្រឹមត្រូវតាមទំរង់ច្បាប់ ប៉ុន្តែបដិសេធចោលដោយខុសនឹងគតិច្បាប់ខ្លះ។

២-តំកល់សាលដីការដ្ឋប្បវេណីលេខ ៧៧"ខ" ចុះថ្ងៃទី២៧ ខែសីហា ឆ្នាំ២០០១ របស់សាលាឧទ្ធរណ៍ទុកជាបានការ លើកលែងតែការតម្រូវឱ្យបើកផ្លូវខាងក្រោយផ្ទះចុងចម្លើយដែលត្រូវទុកជាមោឃៈ ។

៣-បង្វិលសំណុំរឿងរដ្ឋប្បវេណីលេខ ១៨០ ចុះថ្ងៃទី១៧-៦-២០០២ របស់តុលាការកំពូល ទៅសាលាឧទ្ធរណ៍ដើម្បីជំនុំជំរះជាថ្មីឡើងវិញ ត្រង់ចំណុចបើកផ្លូវខាងក្រោយផ្ទះចុងចម្លើយ

៤-រំលែកប្រាក់ប្រដាប់ក្តីដែលដើមចោទ បានបង់ជួសនៅតុលាការកំពូលចំនួន១៩.០០០រគឺ

-ពន្ធចុះបញ្ជីក្តី និងពន្ធហ្វីងចំនួន ៤.០០០រ ប៉ុន្តែប្រាក់នេះត្រូវកាត់ចំនួន ៨០០រ សំរាប់ជារង្វាន់ក្រឡាបញ្ជីកាន់ហិបប្រាក់ ។

-ចំណាយក្នុងកិច្ចប្រគល់ដីកាកោះចំនួន១៥.០០០រ សរុប ១៩.០០០រៀល ។

៥-សាលដីកានេះប្រកាសនាសវនាការជាសាធារណៈនៅថ្ងៃទី១៦ ខែសីហា ឆ្នាំ២០០៤ ។